ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរទន្លេសាប

លេខ :...៦១០.......អទស

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារទទួលបន្ទុកការអនុវត្តគម្រោង ក្រោមកិច្ចសហប្រតិបត្តិការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ADB

## ប្រធានអាជ្ញាធរទន្លេសាប

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៤ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើត អាជ្ញាធរ ទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប
- យោងតាមការចាំបាច់របស់អាជ្ញាធរទន្លេសាប។

### សម្រេច

**ប្រការ ១._**

ត្រូវបានបង្កើតក្រុមការងារទទួលបន្ទុកការអនុវត្តគម្រោង ក្រោមកិច្ចសហប្រតិបត្តិការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ADB មានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | **សរ** | **គីមសាន្ត** | អគ្គលេខាធិការ អាជ្ញាធរទន្លេសាប | ប្រធាន |
| ២- ឯកឧត្តម | **ខុង** | **មាស** | អគ្គលេខាធិការរង អាជ្ញាធរទន្លេសាប | អនុប្រធាន |
| ៣- លោក | **ហេង** | **សុវណ្ណារ៉ា** | ប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស | សមាជិក |
| ៤- លោក | **ខ្វាន់** | **តន្ត្រា** | អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ | សមាជិក |
| ៥- លោក | **ហេង** | **បូរាណ** | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស | សមាជិក |
| ៦- លោក | **ណៅ** | **ណារ៉ាតា** | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស | សមាជិក |
| ៧- លោក | **សាំង** | **វុទ្ធា** | ប្រធានការិយាល័យផែនការ | សមាជិក |
| ៨- លោក | **អ៊ូ** | **ទូច** | ប្រធានការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ | សមាជិក |

| | | | | |
|---|---|---|---|---|
| ៩- លោក | **ព្រាហ្ម** | **សុគំនិត** | អនុប្រធានការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ | សមាជិក |
| ១០- លោក | **ឃាន** | **ច័ន្ទតារា** | អនុប្រធានការិយាល័យភូមិសាស្ត្រ និងផែនទី | សមាជិក |
| ១១- លោក | **ប៉ុម** | **សុម៉ាលី** | អនុប្រធានការិយាល័យរដ្ឋបាល | សមាជិក |
| ១២- លោក | **អ៊ុំចចំរើន** | **រង្សី** | អនុប្រធានការិយាល័យផែនការ | សមាជិក |
| ១៣- លោក | **អ៊ឹង** | **រ៉ាមី** | អនុប្រធានការិយាល័យផែនការ | សមាជិក |
| ១៤- លោក | **រិទ្ធ** | **រតនា** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| ១៥- លោក | **ទី** | **ណារ៉ូ** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| ១៦- លោក | **ចុង** | **សុខលាង** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |

**ប្រការ ២.**_

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលរៀបចំគម្រោងផែនការទាក់ទងការងារគ្រប់គ្រងតំបន់បឹងទន្លេសាបជាមួយ ADB, EIB និងAIIB
- អនុវត្តគម្រោងដែលទទួលហិរញ្ញប្បទានពីធនាគារ ADB, EIB និងAIIB សម្រាប់ការងារពាក់ព័ន្ធអាជ្ញាធរទន្លេសាប
- ពិនិត្យ តាមដាន វាយតម្លៃលើដំណើរការនៃការអនុវត្តគម្រោង ដើម្បីធានាបាននូវគុណភាព ប្រសិទ្ធភាព និងការអនុវត្តការងារចំទិសដៅ
- ធានាឱ្យគម្រោងទាំងអស់អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ចូលរួមដឹកនាំ និងសម្របសម្រួលរាល់កិច្ចការងារផ្សេងៗ ក្នុងករណីការអនុវត្តរបស់គម្រោង មានភាពអសកម្ម ឬមានបញ្ហាឧបសគ្គរាំងស្ទះ
- ទទួលខុសត្រូវ និងអនុវត្តគម្រោងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ហើយធានាបានសុក្រឹតភាព
- រៀបចំរបាយការណ៍វឌ្ឍនភាពអនុវត្តគម្រោង ជូនថ្នាក់ដឹកនាំ អាជ្ញាធរទន្លេសាប
- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗទៀត ដែលឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប ប្រគល់ជូន

**ប្រការ ៣.**_

ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទអាជ្ញាធរទន្លេសាប ឱ្យជួយការងារតាមការចាំបាច់។

**ប្រការ ៤.**_

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.**_

អនុប្រធានអាជ្ញាធរទន្លេសាប អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានគ្រប់នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១២ រោច ខែបឋមាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០២៥

**ប្រធាន**

**ថោ_ជេដ្ឋា**

**ចម្លងជូន៖**

- ក្រសួងធនធានទឹក និងឧតុនិយម
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ដូចក្នុងប្រការ ៥
- ឯកសារ-កាលប្បវត្តិ